**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់**

លេខ ......................../គឃស

រាជធានីភ្នំពេញ ថ្ងៃទី...១៧...ខែ...មករា.....ឆ្នាំ២០០៦

**ជំរាបមក**

**ឯកឧត្តមអភិបាលគ្រប់ខេត្ត ក្រុង និង ជាប្រធានក្រុមការងារ**

**គណនេយ្យភាពមូលនិធិឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុង**

**កម្មវត្ថុ** : ពង្រឹងការអនុវត្តតួនាទី និង ភារកិច្ចរបស់ក្រុមការងារគណនេយ្យភាពមូលធិនិឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុង។

**យោង**: - សេចក្តីសំរេចលេខ ០០២ សសរ / គ.ឃ.ស ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៥ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ស្តីពីការបង្កើតក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់ថ្នាក់ជាតិ។

- សេចក្តីសំរេចលេខ ០២៨ សសរ / គ.ឃ.ស ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ស្តីពីការបង្កើតក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុង។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបឯកឧត្តមអភិបាលខេត្ត ក្រុង និង ជាប្រធានក្រុមការងារគណនេយ្យភាពមូលធិនិឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុងជ្រាបថា ដើម្បីជំរុញការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមការងារគណនេយ្យភាពមូលធិនិឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ គណៈកម្មាធិកាជាតិគាំទ្រឃុំ សង្កាត់ សូមធ្វើការណែនាំដល់ខេត្ត ក្រុងទាំងអស់ដូចតទៅ÷

១-គ្រប់ខេត្ត ក្រុងទាំងអស់ត្រូវរៀបចំប្រជុំក្រុមការងារគណនេយ្យភាពមូលធិនិឃុំ សង្កាត់ ឱ្យបានទៀងទាត់យ៉ាងតិច ១ ដងក្នុង ១ ខែ ដូចមានចែងក្នុងប្រការ ៩ នៃសេចក្តីសំរេចលេខ ០២៨ ស ស រ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់។

២-ប្រធានក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់ខេត្ត ក្រុង ត្រូវចាត់ចែងអនុវត្តតួនាទី មុខងារ និង ភារកិច្ចរបស់ក្រុមគណនេយ្យភាព ដូចមានចែងក្នុងប្រការ ៤ នៃសេចក្តីសំរេចលេខ ០២៨ ស ស រ/ គ.ឃ.ស ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៥ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ស្តីពីការបង្កើតក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់នៅថ្នាក់ខេត្ត ក្រុង។

៣-គ្រប់ខេត្ត ក្រុងទាំងអស់ ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទប្រជុំ របស់ក្រុមការងារគណនេយ្យភាពមូលធិនិឃុំ សង្កាត់ ជាប្រចាំរបស់ខ្លួនមកក្រុមការងារគណនេយ្យភាពមូលធិនិឃុំ សង្កាត់ថ្នាក់ជាតិ ឱ្យបានយ៉ាងតិច ៣ ថ្ងៃមុនការរៀបចំប្រជុំ ដោយគិតតែថ្ងៃធ្វើការ តាមរយៈអាសយដ្ឋានអ៊ីម៉ែល : **national_awg@yahoo.com**។/



មហាវិថីព្រះនរោត្តម : គណៈកម្មាធិការជាតិគាំទ្រ ឃុំ សង្កាត់ ( ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានរដ្ឋបាល នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ) ទូរស័ព្ទ ទូរសារ (០២៣) ២១ ៥០ ៩៤
Norodom Blv, The National Committee to Support Communes «NCSC» ( Ministry of Interior , Department General of Administration , Dep of Local Administration) Fax (023) 21 50 94

៤-ក្រុមការងារគណនេយ្យភាពមូលធិនិយុំ សង្កាត់ថ្នាក់ខេត្ត ក្រុង ត្រូវផ្ញើរបាយការណ៍រីកចំរើនប្រចាំខែមកគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ក្រុមការងារគណនេយ្យភាពមូលធិនិឃុំ សង្កាត់ថ្នាក់ជាតិ តាមរយៈនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ យ៉ាងយូរត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ ។

សូមជូនភ្ជាប់មកជាមួយនូវទំរង់របាយការណ៍រីកចំរើនប្រចាំខែ ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ សូមឯកឧត្តមអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាព ។

**ជ.សហប្រធានគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់**

**សមាជិករដ្ឋមន្ត្រី**

សារ់_សៀ

**<u>ចម្លងជូន</u>** :

-ក្រសួង ស្ថាប័នជាសមាជិកគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

- គណៈកម្មាធិការដឹកនាំកម្មវិធីសីលា

  (ដើម្បីជូនជ្រាប)

- ឯកសារ-កាលប្បវត្តិ